# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

## របាយការណ៍
## ស្ដីពី
## ការត្រួតពិនិត្យគុណភាពនៃការធ្វើតេស្តរកមេរោគអេដស៍ សម្រាប់អ្នកផ្តល់ប្រឹក្សា និងអ្នកធ្វើតេស្ត ឈាមនៅសេវា VCCT

ថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៤ ដោយការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិច្ឆា** ប្រធានមជ្ឈមណ្ឌលជាតិ **លោកវេជ្ជបណ្ឌិត លឹម យី** អនុប្រធានមជ្ឈមណ្ឌលជាតិ រួមអមដំណើរដោយមន្រ្តីជំនាញនៃការិយាល័យបច្ចេកទេស និងផ្នែកជំនាញពាក់ព័ន្ធ នៃមជ្ឈមណ្ឌលជាតិបានដឹកនាំរៀបចំសិក្ខាសាលាស្តីពី ការពង្រឹងចំណេះដឹងការធ្វើតេស្តរកមេរោគអេដស៍ និងវាយតម្លៃលទ្ធផលតេស្ត HIV និង Recency Assay ក្នុងការអនុវត្តកម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២៤ ដល់ ២៨ ខែមិថុនា ឆ្នាំ ២០២៤ នៅសណ្ឋាគារភាពសុខុម ខេត្តកំពត។

វគ្គសិក្ខាសាលានេះក្រោមអធិបតីភាពរបស់ **លោកវេជ្ជបណ្ឌិត លឹម យី** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងរយៈពេល ៣០នាទី នៃការសំណេះសំណាលរបស់គណៈធិបតី លោកបានមានចំណាប់អារម្មណ៍ថាលោកមានក្តីសប្បាយរីករាយណាស់ដែលបានចូលរួមក្នុងវគ្គសិក្ខាសាលាដែលវគ្គនេះមានការចូលរួមពីលោក លោកស្រីអ្នកផ្តល់ប្រឹក្សា និងអ្នកធ្វើតេស្តឈាមនៅសេវា VCCT ក្នុងការកសាងសមត្ថភាពក៏ដូចជាពង្រឹងនូវចំណេះដឹង ក្នុងការត្រួតពិនិត្យគុណភាពនៃការធ្វើតេស្តរកមេរោគអេដស៍ សម្រាប់អ្នកផ្តល់ប្រឹក្សា និងអ្នកធ្វើតេស្តឈាមនៅសេវា VCCT នៃកម្មវិធីអេដស៍ និងកាមរោគ ប្រកបដោយប្រសិទ្ធិភាព និងសុក្រិត្យភាពស្របទៅនឹងកម្មវិធីថ្នាក់ជាតិ ហើយលោកក៏បានផ្តាំផ្ញើរអោយសិក្ខាកាមត្រូវលើកកំពស់ ស្មារតី និងយកចិត្តទុកដាក់ ក្នុងការចូលរួមឱ្យបានស៊ីជម្រៅ និងយល់កាន់តែច្បាស់អំពីជំនាញផ្សេងៗ។ នៅចុងបញ្ចប់លោកក៏បានជូនពរដល់សិក្ខាកាមទាំងអស់ដែលចូលរួមក្នុងវគ្គនេះឱ្យជួបតែសេចក្តីសុខ និងមានសុខភាពល្អដើម្បីចូលរួមជាប្រយោជន៍ ក្នុងវគ្គសិក្ខាសាលានេះរួមប្រកាសបើកវគ្គសិក្ខាសាលានៅវេលាម៉ោង ៩.០០នាទី ។

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីតំណាង US-CDC, ផ្នែកជំនាញនៃមជ្ឈមណ្ឌលជាតិ លោក លោកស្រីអ្នកផ្តល់ប្រឹក្សា និងអ្នកធ្វើតេស្តឈាមនៅសេវា VCCT ១៤ រាជធានី ខេត្ត និងក្រុមការងារបច្ចេកទេសដែលពាក់ព័ន្ធ ។



| ម៉ោង | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| **ថ្ងៃទី ០១ ៖** ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ | | |
| ៧:៣០-៨:០០ | ការចុះឈ្មោះ | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៨:០០-៩:០០ | ពិធីបើកវគ្គបណ្តុះបណ្តាល៖ ចំណាប់អារម្មណ៍ និងការប្រកាសបើកវគ្គបណ្តុះបណ្តាលដោយ លោកវេជ្ជ. លឹម យី អនុប្រធានមជ្ឈមណ្ឌលជាតិ | លោកវេជ្ជ. លឹម យី |
| ៩:០០-៩:១៥ | សម្រាកពិសារអាហារសម្រន់ | |
| ៩:១៥-៩:៤៥ | ១.ការបង្ហាញពីគោលបំណងនៃវគ្គបណ្តុះបណ្តាល<br>២. ការបង្ហាញខ្លួន<br>៣. ការរំពឹងទុក និងការព្រួយបារម្ភ<br>៤. បទបញ្ញត្តិជាក្រុម<br>៥. ការធ្វើតេស្តសាកល្បងមុនវគ្គបណ្តុះបណ្តាល | លោក ហេង សុផាត<br>កញ្ញា វ៉ាត ស្រីពេជ្រ |
| ៩:៤៥-១០:៣០ | **ទិដ្ឋភាពរួមស្តីអំពី** HTS | វេជ្ជ. ជា ច័ន្ទកុសលមុនី<br>វេជ្ជ. គឹម ប៊ុណ្ណា |
| ១០:៣០-១១.១៥ | ១. ចំណេះដឹងជាមូលដ្ឋាន ស្តីអំពី មេរោគអេដស៍ | វេជ្ជ. ជា ច័ន្ទកុសលមុនី |
| ១១.១៥-១២.០០ | ២. ចំណេះដឹងជាមូលដ្ឋាន ស្តីអំពី មេរោគស្វាយ | លោក ម៉ុម ច័ន្ទតារ៉ា |
| ១២:០០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៣:៣០-១៤:២០ | ៣.ក្រមសីលធម៌ និងច្បាប់ពាក់ព័ន្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ | លោកស្រី លឹម សុផារី |
| ១៤:២០-១៥:២០ | ៤.យុទ្ធសាស្ត្រ និងគំនូសបំព្រួញជាតិសម្រាប់ការធ្វើតេស្តរកមេរោគអេដស៍ និងជំងឺអេដស៍ និងទំនាក់ទំនងនៃសេវាផ្តល់ប្រឹក្សា និងសេវាព្យាបាល | លោក ម៉ុម ច័ន្ទតារា |
| ១៥:២០-១៥:៣៥ | **សម្រាកអាហារសម្រន់** | |
| ១៥.៣៥-១៧.០០ | ៥. សុវត្ថិភាពនៅកន្លែងធ្វើតេស្ត និងការរៀបចំសម្ភារៈប្រតិករ | លោកស្រី ពេជ្រ សុបញ្ញា |

| | | |
|---|---|---|
| | -វាយតំលៃវគ្គបណ្តុះបណ្តាលប្រចាំថ្ងៃ | |
| **ថ្ងៃទី ០២ ៖** ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ | | |
| ៨:០០-៨:៣០ | រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី១ | លោកស្រី ពេជ្រ សុបញ្ញា |
| ៨:៣០-៩:៤៥ | ៦. ការយកសំណាកឈាម និងការធ្វើតេស្តរហ័សរកមេរោគអេដស៍ -ស្វាយ និងការទស្សនាវីដេអូ នៃការធ្វើតេស្តឈាមរកមេរោគអេដស៍ស្វាយ | លោក ម៉ុម ច័ន្ទតារា<br>វេជ្ជ.គីម ប៊ុណ្ណា |
| ៩:៤៥-១០:០០ | សម្រាកពិសារអាហារសម្រន់ | |
| ១០:០០-១១:០០ | ៧.ដំណើរការនៃការធ្វើតេស្តដោយខ្លួនឯងHIVST (Ora quick) | វេជ្ជ.គីម ប៊ុណ្ណា<br>លោក ហេង សុផាត |
| ១១:០០-១២:០០ | ៨. ការធានាគុណភាព នៃការធ្វើតេស្តរហ័សរកមេរោគអេដស៍ | លោក អម ច័ន្ទថន |
| ១២:០០-១៣:៣០ | សម្រាកថ្ងៃត្រង់ | |
| ១៣:៣០-១៥:០០ | ៨. ការធានាគុណភាព នៃការធ្វើតេស្តរហ័សរកមេរោគអេដស៍(ត) | លោក អម ច័ន្ទថន |
| ១៥:០០-១៥:១៥ | សម្រាកពិសារអាហារសម្រន់ | |
| ១៥:១៥-១៦:៤៥ | **-អនុវត្តន៍៖** ការធ្វើតេស្ត រកមេរោគអេដស៍មេរោគស្វាយ(Determine HIV, SD Bio line, Ora quick Test, IQC) | លោក អម ច័ន្ទថន<br>លោក ម៉ុម ច័ន្ទតារា<br>លោកស្រី ពេជ្រ សុបញ្ញា |
| ១៦:៤៥-១៧:០០ | -វាយតំលៃប្រចាំថ្ងៃ | លោកស្រី លឹម សុផារី |
| **ថ្ងៃទី ០៣ ៖** ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤ | | |
| ៨:០០-៨:៣០ | រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី២ | លោក អម ច័ន្ទថន |
| ៨:៣០-៩:៣០ | **-អនុវត្តន៍៖** ការយកឈាមចេញពីចុងម្រាមដៃ និងការធ្វើតេស្តរកមេរោគអេដស៍មេរោគស្វាយ (Determine HIV, SD Bio line) | ទាំងអស់គ្នា |
| ៩:៣០-៩:៤៥ | សម្រាកពិសារអាហារសម្រន់ | |
| ៩:៤៥-១២:០០ | **-អនុវត្តន៍៖** ការបកស្រាយលទ្ធផល និងការពិភាក្សាពីការធ្វើតេស្តរកមេរោគអេដស៍មេរោគស្វាយ(Determine HIV, SD Bio line, Ora Quick Test, IQC) | ទាំងអស់គ្នា |
| ១២:០០ - ១៣.៣០ | សម្រាកថ្ងៃត្រង់ | |
| ១៣:៣០-១៥:៣០ | ៩. ការផ្តល់ប្រឹក្សា និងការផ្តល់ប្រឹក្សាជម្រុញលើកទឹកចិត្ត | វេជ្ជ. ជា ច័ន្ទកុសលមុនី<br>លោក ហេង សុផាត |
| ១៥:៣០-១៥:៤៥ | សម្រាកពិសារអាហារសម្រន់ | |
| ១៥:៤៥-១៧:០០ | ៩. ការផ្តល់ប្រឹក្សា និងការផ្តល់ប្រឹក្សាជម្រុញលើកទឹកចិត្ត<br>-វាយតំលៃវគ្គបណ្តុះបណ្តាលប្រចាំថ្ងៃ | លោក ហេង សុផាត<br>វេជ្ជ.ជា ច័ន្ទកុសលមុនី |
| **ថ្ងៃទី ០៤ ៖** ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ | | |
| ៨:០០-៨:៣០ | រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី៣ | លោក ហេង សុផាត |

| | | |
|---|---|---|
| ៨:៣០-៩:៤៥ | -ការអនុវត្តន៍ ៖ សម្តែងតួ | លោក ហេង សុផាត |
| ៩:៤៥-១០:០០ | សម្រាកពិសារអាហារសម្រន់ | |
| ១០:០០-១២.០០ | ១០.ឯកសារកំណត់ត្រា និងរបាយការណ៍<br>- ការអនុវត្តន៍ ៖ ចុះបញ្ជី | លោកឡេង ច័ន្ទរតនា<br>លោកស្រី លឹម សុផារី |
| ១២:០០-១៣:៣០ | សម្រាកថ្ងៃត្រង់ | |
| ១៣:៣០-១៤:០០ | - ការអនុវត្តន៍ ៖ ចុះបញ្ជី | លោកឡេង ច័ន្ទរតនា<br>លោកស្រី លឹម សុផារី |
| ១៤:០០-១៥:១៥ | ១១. ការគ្រប់គ្រងសម្ភារៈប្រតិករ | លោកស្រី លឹម សុផារី |
| ១៥:១៥-១៦:១៥ | - ការអនុវត្តន៍៖ ការស្នើសុំតេស្តប្រតិករ | លោកស្រី លឹម សុផារី |
| ១៥:១៥-១៦:៣០ | សម្រាកអាហារសម្រន់ | |
| ១៦:៣០-១៧:០០ | តេស្តក្រោយវគ្គបណ្តុះបណ្តាល<br>វាយតម្លៃប្រចាំថ្ងៃ | លោកស្រី នុត រតនា |
| **ថ្ងៃទី ០៥ ៖** ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ | | |
| ៨:០០-៨:៣០ | រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី ៤ | លោកស្រី លឹម សុផារី |
| ៨:៣០-៩:៤៥ | -ការបង្ហាញលទ្ធផលតេស្តមុន និងក្រោយវគ្គបណ្តុះបណ្តាល | វេជ្ជ. គីម ប៊ុណ្ណា |
| ៩:៤៥-១០:០០ | សម្រាកពិសារអាហារសម្រន់ | |
| ១០:០០-១២:០០ | ១២. បញ្ជីផ្ទៀងផ្ទាត់ពីដំណើរការជាជំហ៊ានសម្រាប់កែលម្អគុណភាពតេស្តរហ័សរកមេរោគអេដស៍ | វេជ្ជ. គីម ប៊ុណ្ណា |
| ១២:០០-១៤:០០ | សម្រាកថ្ងៃត្រង់ | |
| ១៤:០០-១៥:៣០ | ១២. បញ្ជីផ្ទៀងផ្ទាត់ពីដំណើរការជាជំហ៊ានសម្រាប់កែលម្អគុណភាពតេស្តរហ័សរកមេរោគអេដស៍ (ត) | លោក អម ច័ន្ទថន |
| ១៥:៣០-១៥:៤៥ | សម្រាកពិសារអាហារសម្រន់ | |
| ១៦:៣០-១៦:៤៥ | - ការវាយតម្លៃវគ្គបណ្តុះបណ្តាល និងការបង្ហាញលទ្ធផល | លោក ហេង សុផាត |
| ១៦:៤៥-១៧:០០ | ការបិទវគ្គបណ្តុះបណ្តាល | វេជ្ជ. លឹម យី |